ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១៥ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការបង្រៀន និងរៀន ក្នុងបរិបទកូវីដ-១៩ និងការជំរុញការចាក់វ៉ាក់សាំងការពារកូវីដ-១៩ ដល់បុគ្គលិកអប់រំ និងសិស្សានុសិស្ស

បន្ទាប់ពីការបើកបវេសនកាលឆ្នាំសិក្សា ២០២១-២០២២ នាថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ គ្រឹះស្ថានសិក្សាចំណេះទូទៅទាំងសាធារណៈ និងឯកជន បាននិងកំពុងដំណើរការដោយរលូន និងអនុវត្តបានយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) ព្រមទាំងសេចក្តីណែនាំនានារបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល។ ដើម្បីបន្តចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសប្រភេទអូមីក្រុង និងដើម្បីធានាបន្តនិរន្តរភាពនៃដំណើរការបង្រៀន និងរៀន ឈានទៅបញ្ចប់ឆ្នាំសិក្សាបានពេញលេញ ក្រសួងអប់រំ យុវជន និងកីឡា សូមណែនាំអនុវត្តនូវសកម្មភាពគន្លឹះមួយចំនួន ដូចខាងក្រោម៖

## ១. ដំណើរការបង្រៀននិងរៀន

១. គ្រឹះស្ថានសិក្សាដែលមានសិស្សច្រើន ត្រូវរិះរកវិធានការកាត់បន្ថយចំនួនសិស្សមកសាលារៀនដោយផ្ទាល់ ដោយត្រូវរៀបចំការរៀនឆ្លាស់វេន (ឧទាហរណ៍ មួយសប្តាហ៍សិស្សត្រូវមកថ្នាក់រៀន និងមួយសប្តាហ៍ទៀតសិស្សត្រូវរៀនតាមអនឡាញ ឬ រៀនពីចម្ងាយ)

២. គ្រឹះស្ថានសិក្សា ត្រូវរិះរកវិធានការកាត់បន្ថយចំនួនសិស្សក្នុងថ្នាក់រៀន ដើម្បីរក្សាគម្លាតសុវត្ថិភាព និងលើកកម្ពស់អនាម័យ និងបរិយាកាសល្អនៅក្នុងបន្ទប់រៀន

៣. គ្រឹះស្ថានសិក្សា ត្រូវរៀបចំការបង្រៀន និងរៀនតាមកម្មវិធីសិក្សាបង្រួម ដោយគ្រូបង្រៀនត្រូវសង្ខេបមេរៀន និងបង្រៀនមុខវិជ្ជាសំខាន់ៗ។ ចំពោះមេរៀន និងមុខវិជ្ជាផ្សេងទៀត គ្រូបង្រៀនត្រូវណែនាំសិស្សឱ្យរៀនដោយខ្លួនឯង តាមរយៈការប្រើប្រាស់សម្ភារៈសិក្សា ឬ សន្លឹកមេរៀន ដែលមានស្រាប់ ការសិក្សាក្នុងបណ្ណាល័យ និងការយកឯកសារទៅរៀននៅផ្ទះ

៤. គ្រឹះស្ថានសិក្សា ត្រូវផ្អាកដំណើរការថ្នាក់រៀនជាបណ្តោះអាសន្ន (រយៈពេល ១ សប្តាហ៍ យ៉ាងតិច) ក្នុងករណីរកឃើញថាមានគ្រូបង្រៀន ឬ សិស្សឆ្លងជំងឺកូវីដ-១៩ ហើយត្រូវជំនួសមកវិញ ដោយការបង្រៀនតាមអនឡាញ ឬ ការបង្រៀនពីចម្ងាយ ដោយប្រើវីដេអូឃ្លីប សន្លឹកកិច្ចការ ការបង្រៀន និងរៀនជាបណ្តុំ និងស្វ័យសិក្សា ជាដើម



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

៥. គ្រឹះស្ថានសិក្សា និងគ្រូបង្រៀនទាំងអស់ ត្រូវតែមានការកត់ត្រា និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សឱ្យបានត្រឹមត្រូវ ដើម្បីជាមូលដ្ឋានក្នុងការវិនិច្ឆ័យ និងសម្រេចចិត្ត តាមដំណាក់កាល និងបញ្ចប់ឆ្នាំសិក្សា។

## ២. ការជំរុញការចាក់វ៉ាក់សាំងការពារកូវីដ-១៩ ដល់បុគ្គលិកអប់រំ និងសិស្សានុសិស្ស

១. គ្រូទទួលបន្ទុកថ្នាក់ ត្រូវស្រង់ស្ថិតិសិស្សានុសិស្ស ដែលបានចាក់ និងមិនទាន់បានចាក់វ៉ាក់សាំង ដូសមូលដ្ឋាន (ដូសទី១ និងទី២) និងដូសជំរុញ (ដូសទី៣) រួចបញ្ជូនទៅគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ដើម្បីធ្វើការបូកសរុប

២. គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ត្រូវរៀបចំបូកសរុបស្ថិតិបុគ្គលិកអប់រំ និងសិស្សានុសិស្ស ដែលបានចាក់ និងមិនទាន់ចាក់វ៉ាក់សាំង ដូសមូលដ្ឋាន និងដូសជំរុញ

៣. គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ត្រូវផ្សព្វផ្សាយ និងជំរុញបន្ថែមដល់បុគ្គលិកអប់រំ សិស្សានុសិស្ស ឱ្យទៅចាក់វ៉ាក់សាំងឱ្យបានគ្រប់ៗគ្នា

៤. គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា អាចស្នើសុំ គណៈកម្មការចាក់វ៉ាក់សាំងនៅតាមមូលដ្ឋានរបស់ខ្លួន (មណ្ឌលសុខភាព ឬ មន្ទីរពេទ្យបង្អែក) ចុះទៅចាក់វ៉ាក់សាំងដល់បុគ្គលិកអប់រំ និងសិស្សានុសិស្ស ដោយផ្ទាល់នៅតាមសាលារៀន

៥. ចំពោះគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រូបង្រៀនថ្នាក់មត្តេយ្យ ដែលមានកុមារអាយុ ៣ឆ្នាំ ទៅ ៥ឆ្នាំ សូមផ្សព្វផ្សាយ និងជំរុញដល់មាតាបិតា អ្នកអាណាព្យាបាល ឱ្យនាំកូនចៅទៅចាក់វ៉ាក់សាំងដូសទី១

៦. អាជ្ញាធរដែនដី និងភ្នាក់ងារសុខាភិបាលពាក់ព័ន្ធ សូមជួយសម្របសម្រួល និងជំរុញដំណើរការចាក់វ៉ាក់សាំងដល់បុគ្គលិកអប់រំ និងសិស្សានុសិស្សឱ្យទទួលបានជោគជ័យ។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ កម្រងសាលារៀន និងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន អាជ្ញាធរដែនដី ភ្នាក់ងារសុខាភិបាល មាតាបិតា អ្នកអាណាព្យាបាល ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ២រោច ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**

- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

**"ដើម្បីជ្រាបជាព័ត៌មាន"**

- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា

**"ដើម្បីអនុវត្ត"**

- កាលប្បវត្តិ ឯកសារ នាយកដ្ឋានរដ្ឋបាល